# ការវិភាគរបស់ ម.ស.ម.ក នៅលើសេចក្តីព្រាងច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល និងអនុសាសន៍សំខាន់ៗ

## ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៥

នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៥ គណៈរដ្ឋមន្ត្រី បានអនុម័តសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (“ច្បាប់អង្គការសមាគម”) លើកទី ៥។ បន្ទាប់ពីមានការកែប្រែបន្តិចបន្តួចទៅលើអត្ថបទច្បាប់ ដែលរួមបញ្ចូលការលុបចោលនូវការដាក់កំហិតចំនួន ២៥ % លើខ្ទង់ចំណាយផ្នែករដ្ឋបាល សេចក្តីព្រាងច្បាប់នេះ ត្រូវបានបញ្ជូនទៅកាន់រដ្ឋសភានៅពាក់កណ្តាលខែមិថុនា។

ក្រោយពីសិក្ខាសាលាបង្គ្រប់កិច្ចមួយស្តីពី ការស្វែងយល់អំពីសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៥ សេចក្តីព្រួយបារម្ភតិចតួចប៉ុណ្ណោះដែលត្រូវបានយកមកពិចារណា។ នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ រដ្ឋសភាបានអនុម័តសេចក្តីព្រាងច្បាប់អង្គការសមាគម ដោយមានការកែប្រែតិចតួចបំផុត បើទោះបីជាមានការធ្វើពហិការពីគណបក្សជំទាស់ក្នុងការចូលរួមក្នុងសម័យប្រជុំរដ្ឋសភា និងមានការអំពាវនាវជាច្រើនឲ្យបញ្ឈប់ដំណើរការតាក់តែងច្បាប់ និងរៀបចំកិច្ចពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយតួអង្គពាក់ព័ន្ធផ្សេងទៀត ឬក៏បដិសេធច្បាប់តែម្តងយ៉ាងណាក្តី។

សេចក្តីព្រាងច្បាប់ ដែលមិនទាន់ផ្សព្វផ្សាយជាសាធារណៈ និងផ្លូវការនេះ នៅតែជាសេចក្តីព្រាងច្បាប់មួយដែលមានចំណុចព្រួយបារម្ភជាច្រើន។ ថ្វីបើមានការកែប្រែក្នុងមាត្រា ៥ ដែលបានចែងពីការហាមឃាត់ថ្នាក់ដឹកនាំអង្គការ ឬសមាគមដែលធ្លាប់ត្រូវបានរំលាយ ក្នុងការបង្កើតសមាគមថ្មី ត្រូវបានលុបចោល និងមានការស្វាគមន៍ចំពោះការកាត់បន្ថយចំនួនសមាជិកស្ថាបនិកពី ៥ នាក់ ទៅត្រឹម ៣ នាក់ ក៏ដោយ តែការកែប្រែទាំងនោះមិនអាចដោះស្រាយបញ្ហាសំខាន់ៗជាច្រើនពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់នោះទេ។ ច្បាប់នេះ នៅតែប្រគល់អំណាចដ៏ទូលាយដល់រដ្ឋាភិបាល ដែលអាចធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់លទ្ធភាពដំណើរការរបស់អង្គការសង្គមស៊ីវិលនៅកម្ពុជា។ ប្រសិនបើច្បាប់នេះត្រូវអនុម័ត និងប្រកាសឲ្យប្រើ នោះច្បាប់នេះនឹងបណ្តាលឲ្យមានការបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិសេរីភាពខាងសមាគម សិទ្ធិសេរីភាពបញ្ចេញមតិ សិទ្ធិសេរីភាពខាងការជួបប្រជុំ និងសិទ្ធិចូលរួមក្នុង

ជីវភាពសាធារណៈ ដែលផ្ទុយគ្នាស្រលះនឹងរដ្ឋធម្មនុញ្ញកម្ពុជា និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងលិខិតូបករណ៍អន្តរជាតិពាក់ព័ន្ធដទៃទៀត។

គោលបំណងនៃការវិភាគនេះ មិនមែនជាការវិភាគទៅលើមួយមាត្រាម្តងៗនៃសេចក្តីព្រាងច្បាប់ថ្មីនោះទេ ប៉ុន្តែនឹងបង្ហាញនូវចំណុចព្រួយបារម្ភសំខាន់ៗនៅក្នុងច្បាប់នេះ។

**អង្គការសហគមន៍មូលដ្ឋាន គួរតែត្រូវបានចែងដោយចំហថាមិនស្ថិតក្នុងវិសាលភាពនៃច្បាប់នេះនោះទេ (មាត្រា ៤)**។ តាំងពីការចែកផ្សាយនៃសេចក្តីព្រាងដំបូង ម.ស.ម.ក តែងបង្ហាញការព្រួយបារម្ភជុំវិញការអនុវត្តច្បាប់អង្គការសមាគម លើអង្គការសហគមន៍មូលដ្ឋាន និងចលនាប្រជាជនមិនផ្លូវការផ្សេងៗទៀត។ ថ្វីបើមានការធានាដោយមិនផ្លូវការថាច្បាប់នេះនឹងមិនត្រូវបានប្រើប្រាស់ដើម្បីរឹតបន្តឹងចលនានៅសហគមន៍ក៏ដោយ[1] ប៉ុន្តែសេចក្តីព្រាងច្បាប់នេះមិនបានបរិយាយឲ្យបានជាក់លាក់ពីការមិនអនុវត្តលើអង្គការសហគមន៍មូលដ្ឋាននោះទេ ដែលទុកចន្លោះឲ្យអាជ្ញាធរអាចបកស្រាយ ថាគួរបញ្ចូលអង្គការទាំងនេះក្នុងប្រភេទសមាគមឬ ក៏អត់។ បញ្ហានេះជាបញ្ហាប្រឈមជាក់ស្តែងដែលអាជ្ញាធរ និងកងកម្លាំងសន្តិសុខអាច ប្រើប្រាស់បញ្ញត្តិនេះខុស ឬពន្លើស មិនមែនដើម្បីតែកំហិត ដល់សិទ្ធិសេរីភាពខាងសមាគមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់ដល់សិទ្ធិខាងជួបប្រជុំ និងសិទ្ធិផ្សេងៗទៀតដូចជា សិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសិទ្ធិចូលរួមក្នុងជីវភាពនយោបាយ សង្គម និងសេដ្ឋកិច្ចជាតិផងដែរ។

ម.ស.ម.ក សូមផ្តល់អនុសាសន៍ ៖

- *ស្នើសុំឲ្យកែប្រែមាត្រា ៤ ដើម្បីបញ្ចូលបញ្ញត្តិដែលដកអង្គការសហគមន៍មូលដ្ឋានចេញពីវិសាលភាពនៃច្បាប់នេះ។*

**ការចុះបញ្ជីជាចាំបាច់ត្រូវតែលុបចោល (មាត្រា ៦ និង មាត្រា ៩ (២))**។ ការចុះបញ្ជីជាចាំបាច់ គឺជាតម្រូវការ សម្រាប់សមាគម និងអង្គការក្នុងស្រុក ដែលមានបំណងធ្វើសកម្មភាពណាមួយ។ ការបដិសេធមិនត្រឹមតែលើភាពស្របច្បាប់ដល់អង្គការសមាគម ថែមទាំងហាមឃាត់រាល់សកម្មភាពនានាគឺមិនអនុលោមទៅនឹងសិទ្ធិសេរីភាពខាងសមាគមដូចដែលបានចែងក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាត។ការចុះបញ្ជីគួរតែធ្វើឡើងដោយស្ម័គ្រចិត្ត និងមានគោលបំណងក្នុងការស្វែងរកភាពស្របច្បាប់តែប៉ុណ្ណោះ។

ម.ស.ម.ក សូមផ្តល់អនុសាសន៍ ៖

---

[1] ដូចបានលើកឡើងដោយ ឯកឧត្តម សក់ សេដ្ឋា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៥ ក្នុងអំឡុងពេល "សិក្ខាសាលាថ្នាក់ជាតិដើម្បីស្វែងយល់ពីច្បាប់អង្គការសមាគម" ដែលរៀបចំឡើងដោយគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន ដោយសហការជាមួយគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈ និងគណៈកម្មការនីតិកម្ម និងយុត្តិធម៌ របស់រដ្ឋសភា។

- *លុបចោលនូវការចុះបញ្ជីជាចាំបាច់ ដោយលុបចោលមាត្រា ៩ (២) និងកែប្រែមាត្រា ៦ (កែពី "ត្រូវចុះបញ្ជី" ទៅជា "អាចចុះបញ្ជី")។*

**លក្ខខណ្ឌតម្រូវការចុះបញ្ជី ត្រូវតែធ្វើឲ្យមានលក្ខណៈសាមញ្ញ (មាត្រា ៦)** ។ សេចក្តីព្រាងច្បាប់ស្តីពីអង្គការសមាគម ក្នុងពេលបច្ចុប្បន្ន ចែងពីលក្ខខណ្ឌតម្រូវការចុះបញ្ជីយ៉ាងច្រើនសន្ធឹកសន្ធាប់ សម្រាប់ឲ្យសមាគម និងអង្គការទាងអស់បំពេញតាម ដោយមិនគិតពីទំហំ ឬវិសាលភាពនៃស្ថាប័នទាំងនោះនោះទេ។ តម្រូវការទាំងអស់នោះរួមមាន លិខិតចេញដោយអាជ្ញាធរមានសមត្ថកិច្ចក្នុងស្រុក ដោយមានបញ្ជាក់អាសយដ្ឋានទីតាំងការិយាល័យកណ្តាលរបស់សមាគម ឬអង្គការក្នុងស្រុក។ ចំណុចនេះនឹងបង្កជាបន្ទុកយ៉ាងធ្ងន់ធ្ងរសម្រាប់ស្ថាប័នដែលមានទំហំតូច។

ម.ស.ម.ក សូមផ្តល់អនុសាសន៍ ៖

- *កែប្រែមាត្រា ៦ ទៅជាត្រឹមតែតម្រូវឲ្យអ្នកដាក់ពាក្យបញ្ជាក់ពីអាសយដ្ឋាន ប៉ុន្តែមិនចាំបាច់ថាជាអាសយដ្ឋានការិយាល័យកណ្តាលរបស់ខ្លួននោះទេ។*

**ការចុះបញ្ជីរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស** (**មាត្រា ១២ ១៣ និង ១៥**)។ សេចក្តីព្រាងច្បាប់ស្តីពីអង្គការសមាគម បានបង្ហាញពីបញ្ហាធ្ងន់ធ្ងរមួយចំនួន សម្រាប់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមានបំណងធ្វើសកម្មភាពនៅកម្ពុជាផងដែរ។ មាត្រា ១២ បានដាក់កំហិតការចុះបញ្ជីជាចាំបាច់ ក្នុងទម្រង់ជាអនុស្សរណៈ ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ក្នុងករណីដែលជាគម្រោងមានរយៈពេលខ្លី តម្រូវឲ្យមានការសុំអនុញ្ញាតពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមរយៈដៃគូក្នុងស្រុក ហើយពុំមានការពន្យល់អត្ថន័យពាក្យថា «រយៈពេលខ្លី» នោះទេ។ មាត្រា ១៣ កំណត់តម្រូវការដ៏សាំញ៉ាំ រួមមាន លិខិតចេញដោយអាជ្ញាធរមានសមត្ថកិច្ចបរទេស អនុញ្ញាតិឲ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដំណើរការដោយមិនគិតពីច្បាប់អនុវត្តនៅក្នុងប្រទេសប្រភពដើមនោះទេ និងរួមជាមួយនឹងលិខិតគាំទ្រគម្រោងនានារបស់សមាគមដែលចេញដោយក្រសួង ឬស្ថាប័នរាជរដ្ឋាភិបាល។ យោងតាម មាត្រា ១៥ ចែងថា សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ត្រូវតែពិភាក្សាឯកភាពជាមួយក្រសួង ឬស្ថាប័នរបស់រាជរដ្ឋាភិបាលជាដៃគូដែលមិនបានបញ្ជាក់ច្បាស់ពីឈ្មោះរបស់ស្ថាប័នទាំងនេះ លើគម្រោងនានា មុននឹងដាក់ពាក្យសុំចុះអនុស្សារណៈ ដែលនេះទុកចន្លោះឲ្យអាជ្ញាធរប្រើអំណាចជ្រៀតជ្រែកទៅលើសកម្មភាពរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលទាំងនោះ។

ម.ស.ម.ក សូមផ្តល់អនុសាសន៍ ៖

- *ស្នើឲ្យពន្យល់អត្ថន័យនៃពាក្យថា "រយៈពេលខ្លី" ក្នុងមាត្រា ១២*
- *ស្នើឲ្យសម្រួលពីលក្ខខណ្ឌតម្រូវការចុះបញ្ជី តាមរយៈការលុបចោលតម្រូវការចំណុច ៣ និង ៤ ចេញពីមាត្រា ១៣ ដែលតម្រូវឲ្យមានលិខិតចេញពីអាជ្ញាធរមានសមត្ថកិច្ចបរទេសនៃប្រទេសដើម អនុញ្ញាតឲ្យ*

*សមាគម ឬអង្គការបរទេសធ្វើប្រតិបត្តិការ និងលិខិតគាំទ្រនូវរាល់គម្រោងរបស់សមាគម ឬអង្គការបរទេសដែលចេញដោយក្រសួង ឬស្ថាប័ននៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។*

**ការបដិសេធការចុះបញ្ជី ត្រូវតែបញ្ជាក់ជាលាយលក្ខណ៍អក្សរ (មាត្រា ៨ និង ១៤)**។ សេចក្តីព្រាងច្បាប់ថ្មីនេះ មិនបានកំណត់លក្ខខណ្ឌឲ្យបានច្បាស់លាស់ថាឯកសារដាក់ពាក្យសុំចុះបញ្ជីបែបណាខ្លះនឹងត្រូវបដិសេធ។ មាត្រា ៨ ផ្តល់អំណាចឲ្យក្រសួងមហាផ្ទៃ ក្នុងការត្រួតពិនិត្យរាល់ឯកសារស្នើសុំ របស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល និងភាពស្របច្បាប់របស់លក្ខន្តិកៈ ហើយធ្វើការសម្រេចទៅលើពាក្យស្នើសុំទាំងនោះ។ បើទោះបីជាក្រសួងមហាផ្ទៃមានកាតព្វកិច្ចជូនដំណឹងដល់អ្នកស្នើសុំចុះបញ្ជីជាលាយលក្ខណ៍អក្សរក្តី តែសេចក្តីព្រាងច្បាប់នេះមិនបានស្នើឲ្យក្រសួងមហាផ្ទៃ លើកទឹកចិត្ត ឬផ្តល់ដំណឹងពីការសម្រេចចិត្តចុងក្រោយ តាមរយៈលាយលក្ខណ៍អក្សរនោះទេ។ ដូច្នេះ ការស្នើសុំផ្សេងៗ បើកចំហឲ្យមានលទ្ធភាពក្នុងការបដិសេធ យោងលើហេតុផលដ៏ស្មុគ-ស្មាញ។ មាត្រា ៨ កថាខណ្ឌទី ៣ បានចែងថាក្នុងករណីដែលមានការសម្រេចចិត្តយឺតយ៉ាវ (លើសពី ៤៥ ថ្ងៃ នៃថ្ងៃធ្វើការ) សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនឹងត្រូវបានចាត់ទុកថាបានចុះបញ្ជីស្របតាមច្បាប់នេះ ហើយក្រសួងមហាផ្ទៃត្រូវធ្វើ និយ័តកម្មឯកសារចុះបញ្ជីផ្តល់ជូនទៅសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល។ ថ្វីបើនេះជាការវិវត្តវិជ្ជមានមួយ ក៏នៅមានការព្រួយបារម្ភពាក់ព័ន្ធនឹងការអនុវត្តជាក់ស្តែង ស្តីពីបទប្បញ្ញត្តិនេះផងដែរ។ ជាពិសេស ការបញ្ជាក់ថាបានទទួលឯកសារគួរតែត្រូវបានផ្តល់ជូនពេលដាក់ពាក្យស្នើសុំ និងក្លាយជាការបញ្ជាក់ស្របច្បាប់ក្នុងការធ្វើប្រតិបត្តិការ ក្នុងករណីបើមានការចុះបញ្ជីដោយស្វយប្រវត្តិបែបនេះ។ ចំណុចដែលគួរឲ្យព្រួយបារម្ភខ្លាំង គឺបញ្ញត្តិមិនច្បាស់លាស់ដែលមានចែងក្នុងមាត្រា ៨ (៤) ដែលចែងថាក្រសួងមហាផ្ទៃអាចបដិសេធសំណើចុះបញ្ជីពីសមាគម ឬអង្គការក្នុងស្រុកណា ដែលមានគោលបំណង និងគោលដៅ ធ្វើឲ្យប៉ះពាល់ដល់សន្តិសុខសាធារណៈ ស្ថិរភាព និងសណ្តាប់ធ្នាប់ ឬបង្កឲ្យមានការគំរាមកំហែងដល់សន្តិសុខជាតិ ឯកភាពជាតិ ឬវប្បធម៌ ឬទំនៀមទម្លាប់ ឬប្រពៃណីដ៏ល្អរបស់សង្គមជាតិកម្ពុជា។ សេចក្តីព្រាងច្បាប់នេះ គឺមានលក្ខខណ្ឌអាក្រក់ខ្លាំងសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ដូចក្នុង មាត្រា ១៤ ដែលមិនបានកំណត់នូវមូលដ្ឋានក្នុងការបដិសេធសំណើក្នុងការចុះអនុស្សារណៈ ឬក៏តម្រូវឲ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានកាតព្វកិច្ចពន្យល់បន្ថែមពីការសម្រេចចិត្តបដិសេធនោះទេ។

ម.ស.ម.ក សូមផ្តល់អនុសាសន៍ ៖

- *ស្នើឲ្យកែប្រែមាត្រា ៨(២) ដើម្បីបញ្ចូលនូវកាតព្វកិច្ចសម្រាប់ឲ្យក្រសួងមហាផ្ទៃ ដើម្បីលើកទឹកចិត្ត និងទំនាក់ទំនងជាលាយលក្ខណ៍អក្សរ នូវសេចក្តីសម្រេចចុងក្រោយក្នុងការបដិសេធការស្នើសុំចុះបញ្ជី ដើម្បីអាចសម្របសម្រួលនូវសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ចំពោះការសម្រេចចិត្ត*
- *ដើម្បីធានានូវការអនុវត្តជាក់ស្តែងនូវមាត្រា ៨(៣) ដោយរួមបញ្ចូលកាតព្វកិច្ចរបស់ក្រសួងមហាផ្ទៃក្នុងការចេញលិខិតបញ្ជាក់ការទទួលសំណើសុំចុះបញ្ជី ចំពោះគ្រប់ឯកសារដែលតម្រូវឲ្យមានទាំងអស់។*

*លិខិតបញ្ជាក់នេះនឹងក្លាយជាសិទ្ធិស្របច្បាប់សម្រាប់ប្រតិបត្តិការ ក្នុងករណីដែលមានការចុះបញ្ជីដោយស្វ័យប្រវត្តិ។*

- *លុបចោលនូវបញ្ញត្តិមិនច្បាស់លាស់ដែលមានក្នុងមាត្រា ៨(៤) ឬក៏បញ្ជាក់បញ្ញត្តិទាំងនោះឲ្យច្បាស់ដើម្បីអាចបំពេញនូវលក្ខខណ្ឌចាំបាច់ និងសមាមាត្រ។*
- *កែប្រែមាត្រា ១៤ និងរួមបញ្ចូលនូវកាតព្វកិច្ចសម្រាប់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីសរសេរជាលាយលក្ខណ៍អក្សរស្តីពីការបដិសេធនៃសំណើចុះបញ្ជី។*

**លុបចោលតម្រូវការហួសប្រមាណ មិនច្បាស់លាស់ និងជ្រៀតជ្រែកដែលធ្វើឲ្យប្រឈមនឹងការលុបឈ្មោះចេញពីបញ្ជី (មាត្រា ២៤)**។ មាត្រា ២៤ តម្រូវឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ទាំងក្នុងស្រុក និងបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹតចំពោះគ្រប់គណបក្សនយោបាយទាំងអស់ បើមិនដូច្នោះ នឹងត្រូវលុបឈ្មោះចេញពីបញ្ជី។ ថ្វីបើលក្ខខណ្ឌនេះមិនអនុវត្តចំពោះសមាគមក្នុងស្រុកក្តីទុកចន្លោះឲ្យមានការរំលោភបំពានលើសេរីភាពខាងការបញ្ចេញមតិយ៉ាងធ្ងន់ធ្ងរ និងអាចមានការបំពានពីសំណាក់អាជ្ញាធរ ដើម្បីបំបិទសំឡេងប្រឆាំង និងរិះគន់ទៀតផង។ បន្ថែមពីលើនោះ មាត្រា ២៥ បានដាក់កំហិតឲ្យអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ផ្តល់នូវច្បាប់ចម្លងរបាយការណ៍ដែលផ្ញើទៅម្ចាស់ជំនួយ ដែលនេះបង្កើតលក្ខខណ្ឌមិនចាំបាច់ឲ្យរដ្ឋាភិបាលអាចទទួលបានព័ត៌មានរសើបមួយចំនួន។ បន្ថែមពីលើនោះ បញ្ញត្តិនេះក៏បញ្ជាក់ដែលថាសមាគមក្នុងស្រុក អាចនឹងស្នើសុំឲ្យមានការផ្តល់របាយការណ៍ប្រចាំឆ្នាំ "ក្នុងករណីចាំបាច់" ជាបញ្ញត្តិមិនច្បាស់លាស់ហើយអាចងាយស្រួលក្នុងការបំពានបាន។

ម.ស.ម.ក សូមផ្តល់អនុសាសន៍ ៖

- *លុបចោលមាត្រា ២៤ ដោយសារតែមាត្រានេះផ្ទុយនឹងសិទ្ធិសេរីភាពខាងការបញ្ចេញមតិ ដែលរួមទាំងការរិះគន់ផ្នែកនយោបាយផងដែរ។*
- *កែប្រែមាត្រា ២៥ ដោយលុបចោលនូវកាតព្វកិច្ចក្នុងការ*ដាក់សេចក្តីចម្លងនៃរបាយការណ៍ដើម។

**លុបចោលមូលដ្ឋានសំអាងមិនច្បាស់លាស់ក្នុងការលុបឈ្មោះចេញពីបញ្ជី និងទោសប្បញ្ញត្តិ**។ សេចក្តីព្រាងច្បាប់ស្តីពីអង្គការសមាគម ផ្តល់អំណាចយ៉ាងទូលាយដល់ក្រសួងមហាផ្ទៃក្នុងការលុបឈ្មោះចេញពីបញ្ជី។ ចំណុចដែលគួរឲ្យព្រួយបារម្ភជាពិសេស គឺបញ្ញត្តិដែលកំណត់ក្នុងមាត្រា ៣០។ ការផ្អាកសកម្មភាពបណ្តោះអាសន្ន និងការលុបឈ្មោះពីបញ្ជី ដោយសារតែមិនបានគោរពតាមគោលការណ៍អព្យាក្រឹត និងតម្រូវការផ្តល់របាយការណ៍ផ្សេងៗទៀត ដូចមានចែងក្នុងមាត្រា ១០ មាត្រា ២៤ និងមាត្រា ២៥ កថាខណ្ឌទី ២ និង ទី៣ បង្កហានិភ័យខ្ពស់ក្នុងការរំលោភបំពាន។ ការផ្អាកសកម្មភាព ឬក៏លុបឈ្មោះចេញពីបញ្ជី ចំពោះសកម្មភាពដែលផ្ទុយនឹងលក្ខន្តិកៈ គឺជាបញ្ញត្តិដែលជ្រៀតជ្រែក ហើយគ្មានអ្វីខុសប្លែករវាងបញ្ញត្តិក្នុងលក្ខន្តិកៈ និងនាំឲ្យមានការជ្រៀតជ្រែកមិនចាំបាច់លើបញ្ហាផ្ទៃក្នុង។ ចុងក្រោយ បញ្ញត្តិដែលចែងយ៉ាងស្រពេចស្រពិល មាត្រា ៣០ ចែងថា ក្រសួងមហាផ្ទៃត្រូវតែលុប

ឈ្មោះចេញពីបញ្ជី នូវសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលធ្វើសកម្មភាពប៉ះពាល់ដល់សន្តិសុខសាធារណៈ សន្តិភាព ស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កមហន្តរាយដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អរបស់សង្គមជាតិកម្ពុជា ដែលនេះទុកចន្លោះក្នុងការដាក់កំហិតដោយអំពើចិត្តទៅលើសិទ្ធិខាងសមាគម។ ការដាក់កំហិតនេះដូចគ្នានឹងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ដោយយោងតាមបញ្ញត្តិដែលចែងក្នុងមាត្រា ៣៤ និង មាត្រា ៣៥។ ទោសទណ្ឌផ្នែករដ្ឋបាលដ៏ធ្ងន់ធ្ងរក៏ត្រូវបានដាក់ទៅលើសមាគម និងអង្គការដែលធ្វើសកម្មភាពដោយ មិនបានចុះបញ្ជី ឬបន្តសកម្មភាពរបស់ពួកគេ បន្ទាប់ពីត្រូវបានផ្អាកសកម្មភាព ឬលុបឈ្មោះចេញពីបញ្ជីហើយ។

ម.ស.ម.ក សូមផ្តល់អនុសាសន៍ ៖

- *លុបចោលមាត្រា ២៤ ចេញពីមូលដ្ឋានសំអាងក្នុងការលុបឈ្មោះចេញពីបញ្ជី*
- *លុបចោលនូវបញ្ញត្តិដែលមិនច្បាស់លាស់ចែងក្នុងមាត្រា ៣០ (៣) ឬក៏បញ្ជាក់ដើម្បីឲ្យបញ្ញត្តិទាំងនេះអាចបំពេញលក្ខខណ្ឌចាំបាច់ និងសមាមាត្រ*
- *កែប្រែមាត្រា ៣៥ ដើម្បីធានាសិទ្ធិប្តឹងប្រឆាំងនឹងសេចក្តីសម្រេចក្នុងការផ្អាច់សុពលភាពនៃអនុស្សរណៈនៃការយោគយល់។*